**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងរដ្ឋប្បវេណីលេខ៖៣៥២
ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣
**សាលក្រមរដ្ឋប្បវេណី**
**លេខ៖ ០០៥ "ខ"**
ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តតាកែវ**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤
**ចៅក្រមជំនុំជម្រះ**
-លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តតាកែវ
**ក្រឡាបញ្ជីសវនាការ**
-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តតាកែវ

១-ដើមចោទឈ្មោះ [redacted]ស៊ីឡុន ភេទស្រី អាយុ៥០ឆ្នាំ អាសយដ្ឋានភូមិ[redacted]

ដោយមានលោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ

២-ចុងចម្លើយឈ្មោះ [redacted]ណាត ភេទប្រុស អាយុ៤១ឆ្នាំ អាសយដ្ឋាន[redacted]។

**១-អង្គហេតុ និងចំណុចវិវាទ៖**

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១-លែងលះដើមចោទឈ្មោះ [redacted]ស៊ីឡុន និងចុងចម្លើយឈ្មោះ [redacted]ណាត។

២-កំណត់ថាដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូន១នាក់ឈ្មោះ[redacted]ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។

៣-សុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ

**ខ-ដំណើររឿងក្តី និងចំណុចវិវាទ៖**

**ខ.១-ការសង្ខេបអំពីរឿងក្តី៖**

ក្នុងរឿងក្តីនេះ ដើមចោទសុំលែងលះជាមួយចុងចម្លើយ ដោយមូលហេតុថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយបានបែកបាក់ ដោយសារតែចុងចម្លើយបានជេរប្រមាថមកលើដើមចោទ និងសាច់ញាតិដើមចោទនូវពាក្យអសុរសជាច្រើនលើកច្រើនសារ ឱ្យតែផឹកស្រាស្រវឹងម្តងៗ តែងតែមករករឿងឈ្លោះប្រកែកគ្នាជាញឹកញាប់ និងបានប្រើអំពើហិង្សាមកលើដើមចោទថែមទៀត ដែលជាហេតុធ្វើឱ្យដើមចោទមិនអាចទ្រាំរស់នៅជាមួយចុងចម្លើយបាន ទើបដើមចោទបានចុះចេញពីផ្ទះ មករស់នៅខាងម្តាយរបស់ខ្លួនតាំងពីឆ្នាំ២០២២ មកម្ល៉េះ ហើយដើមចោទបានទាមទារនូវការកំណត់ថា ជាអ្នកមានអំណាចមេបាលើកូនចំនួន ១នាក់ឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ និងសុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់។

**ខ.២-អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ៖**

ខ.២.១.ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមប្រពៃណី ហើយបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នា ដោយសង់ផ្ទះនៅលើដីម្តាយរបស់ដើមចោទចែកឱ្យ តែដើមចោទ និងចុងចម្លើយមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់ទេ។

ខ.២.២.ដើមចោទ និងចុងចម្លើយបង្កើតបានកូនចំនួន ២នាក់៖ កូនទី១ឈ្មោះ [redacted] **សុនិតា** ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ និងកូនទី២ឈ្មោះ [redacted]**សុវីរៈ** ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ (ភស្តុតាងសៀវភៅគ្រួសារលេខ៖០៥ ក្រក២៨២៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦)។



Scanned with CamScanner

## ខ.៣-ចំណុចវិវាទ និងការអះអាងរបស់ភាគីចំពោះចំណុចវិវាទ៖

ខ.៣.១.ការលែងលះ

ខ.៣.១.១.ការអះអាងរបស់ដើមចោទ៖

ដើមចោទសុំឱ្យលោកមេធាវីថ្លែងការណ៍អះអាងជំនួសដើមចោទគ្រប់ចំណុច

-លោក ហេង រដ្ឋា ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថា ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី តែមិនបានទៅចុះសំបុត្រ អាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់។ ការរស់នៅជាប្តីប្រពន្ធនឹងគ្នា ចុងចម្លើយមិនបានបំពេញកាតព្វកិច្ចក្នុងការចិញ្ចឹមបីបាច់ថែរក្សាប្រពន្ធកូននោះទេ គឺបានជេរប្រមាថមកលើដើមចោទ និងសាច់ញាតិដើមចោទនូវពាក្យ អសុរសជាច្រើនលើកច្រើនសារ ឱ្យតែផឹកស្រាស្រវឹងម្តងៗ តែងតែមករករឿងឈ្លោះប្រកែកគ្នាជាញឹកញាប់ និងបានប្រើអំពើហិង្សាមកលើដើមចោទថែមទៀតដែលជាហេតុធ្វើឱ្យដើមចោទមិនអាចទ្រាំរស់នៅ ជាមួយចុង ចម្លើយបាន ទើបដើមចោទបានចុះចេញពីផ្ទះមករស់នៅខាងម្តាយរបស់ខ្លួនតាំងពីឆ្នាំ២០២២ មកម្ល៉េះដែលវាផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍។

ខ.៣.១.២.ការអះអាងរបស់ចុងចម្លើយ៖

ចុងចម្លើយយល់ព្រមលែងលះ។

ខ.៣.២.ការកំណត់អំណាចមេបា៖

ខ.៣.២.១.ការអះអាងរបស់ដើមចោទ៖

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍អះអាងថា ការរួមរស់រវាងដើមចោទ និងចុងចម្លើយបង្កើតបានកូនចំនួន ២នាក់៖ កូនទី១ឈ្មោះ [redacted] សុនិតា ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ និងកូនទី២ឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ (ភ័ស្តុតាងសៀវភៅគ្រួសារលេខ៖០៥ គ្រក ២៨២៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦) មូលហេតុដែលដើមចោទសុំគ្រប់គ្រងកូនទី២ ឈ្មោះ [redacted] សុវីរៈ ភេទប្រុសដោយសារតែដើមចោទ ជាម្តាយដែលបីបាច់ថែរក្សា កូនតាំងពីតូចមកម្ល៉េះ ដែលជាហេតុធ្វើឱ្យដើមចោទ និងកូនមានមនោសញ្ចេតនាល្អជាមួយគ្នា លើសពីនេះទៅ ទៀតដើមចោទអាចផ្តល់ការអប់រំល្អជាងចុងចម្លើយ ជាពិសេសដោយសារតែដើមចោទមានលទ្ធភាពគ្រប់គ្រាន់ក្នុង ការទំនុកបម្រុងកូន ម្យ៉ាងទៀត កូននេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដើមចោទស្រាប់។

ខ.៣.២.២.ការអះអាងរបស់ចុងចម្លើយ៖

-ចុងចម្លើយយល់ព្រមប្រគល់សិទ្ធិឱ្យដើមចោទជាអ្នកមានអំណាចមេបាគ្រប់គ្រងលើឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។

ខ.៣.៣-ទ្រព្យសម្បត្តិដោយឡែក៖

ខ.៣.៣.១.ការអះអាងរបស់ដើមចោទ៖

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍អះអាងថា ដីសង់ផ្ទះរស់នៅជាមួយគ្នា គឺជាដីម្តាយខ្លួនចែកឱ្យ និងដីស្រែមួយកន្លែង។

ខ.៣.៣.២.ការអះអាងរបស់ចុងចម្លើយ៖

-ដីសង់ផ្ទះរស់នៅជាមួយគ្នា គឺជាដីម្តាយក្មេកចែកឱ្យ និងដីស្រែមួយកន្លែងនោះ គឺខ្លួនមិនលើកយកមកនិយាយទេ។

ខ.៤.៤-សុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់៖

ខ.៤.៤.១.ការអះអាងរបស់ដើមចោទ៖

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍អះអាងថា ក្នុងការរួមរស់ជាប្តីប្រពន្ធនឹងគ្នា ដើមចោទ និងចុងចម្លើយបានទិញរ៉ឺម៉កម៉ូតូមួយគ្រឿង គឺទិញក្នុងតម្លៃ ១,៥០០(មួយពាន់ប្រាំ



Scanned with CamScanner

រយ)ដុល្លារអាមេរិក តែពេលនេះ ដើមចោទប្រគល់ឱ្យចុងចម្លើយគ្រប់គ្រង និងបានចាក់ដីនិងសាងសង់ផ្ទះនៅលើដីដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ អស់ទឹកប្រាក់សរុប៣.៥០០(បីពាន់ប្រាំរយ)ដុល្លារអាមេរិក នៅពេលនេះ ដើមចោទសុំគ្រប់គ្រងលើផ្ទះ និងដីដោយប្រគល់ប្រាក់ចំនួន២,០០០ (ពីរពាន់)ដុល្លារអាមេរិក ទៀតទៅឱ្យចុងចម្លើយ។

១.៤.៤.២.ការអះអាងរបស់ចុងចម្លើយ៖

-ក្នុងការរួមរស់ជាមួយគ្នារវាងចុងចម្លើយ និងដើមចោទពិតជាបានទិញរ៉ឺម៉កម៉ូតូមួយគ្រឿង ក្នុងតម្លៃ ១.៨០០(មួយពាន់ប្រាំបីរយ)ដុល្លារអាមេរិក ហើយនៅពេលរួមរស់ជាមួយគ្នា ចុងចម្លើយបានយកលុយពីម្តាយរបស់ចុងចម្លើយចំនួន ១២.០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ដើម្បីយកមកចាក់ដី និងសាងសង់ផ្ទះ នៅពេលនេះ ខ្លួនទាមទារប្រាក់ដែលជាចំណែកទ្រព្យរួមរកស៊ីជាមួយគ្នា ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក និងរ៉ឺម៉កម៉ូតូមួយគ្រឿង។

## សម្អាងហេតុ

### ២-ការវិនិច្ឆ័យចំពោះការលែងលះ

### ២.១-ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការទទួលស្គាល់តាមរយៈភ័ស្តុតាង ដូចបានកត់ត្រាគិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ៖

២.១.១.ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី ប៉ុន្តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។

២.១.២.ចុងចម្លើយ ឱ្យតែផឹកស្រវឹងតែងតែរករឿងជាមួយដើមចោទ ប្រើអំពើហិង្សា ទើបដើមចោទចុះចេញពីផ្ទះ ដែលជាហេតុធ្វើឱ្យដើមចោទមិនអាចទ្រាំរស់នៅជាមួយចុងចម្លើយបាន ទើបដើមចោទបាន ចុះចេញពីផ្ទះ មករស់នៅខាងម្តាយរបស់ខ្លួនតាំងពីឆ្នាំ២០២២ មកម្ល៉េះ (លទ្ធផលនៃការសាកសួរភាគី)។

២.១.៣.ចុងចម្លើយឯកភាពចំពោះការទាមទារសុំលែងលះរបស់ដើមចោទ។

### ២-២.សេចក្តីសន្និដ្ឋាន

ផ្អែកតាមសរុបនូវអង្គហេតុទទួលស្គាល់ក្នុងចំណុច(២.១)ខាងលើ តុលាការទទួលថា ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងរួមរស់នៅជាមួយគ្នា រហូតមកដល់ពេលបច្ចុប្បន្ននេះ ប៉ុន្តែ ការរួមរស់ជាមួយគ្នារវាងដើមចោទ និងចុងចម្លើយ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមលក្ខខណ្ឌដែលច្បាប់តម្រូវយោងមាត្រា៩៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ដូច្នេះដើមចោទ និងចុងចម្លើយមិនមែនជាសហព័ទ្ធនឹងគ្នាឡើយ។ ប៉ុន្តែ ការរួមរស់ជាមួយគ្នារវាងដើមចោទ និងចុងចម្លើយតុលាការទទួលស្គាល់ថាជាការរស់នៅបែបអនីតិសង្វាស។ ការរួមរស់រវាងដើមចោទ និងចុងចម្លើយតែងតែមានទំនាស់គ្នាជាញឹកញាប់ មិនចុះសម្រុងនឹងគ្នា ជាពិសេសដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាឈប់រស់នៅបែបជាអនីតិសង្វាស់ ហេតុដូច្នេះ គប្បីតុលាការ សម្រេចតាមការព្រមព្រៀងរវាងដើមចោទ និងចុងចម្លើយ។

### ៣.ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា៖

### ៣.១-ការទទួលស្គាល់អង្គហេតុ៖

៣.១.១-ការរួមរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយបង្កើតបានកូនចំនួន២នាក់៖ កូនទី១ឈ្មោះ [redacted]សុនិតា ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ និងកូនទី២ឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ (ភ័ស្តុតាងសៀវភៅគ្រួសារលេខ៖០៥គ្រក ២៨២៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦)។ ចំពោះកូនទី១ឈ្មោះ [redacted] សុនិតា ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ គ្រប់នីតិភាពហើយ ដើមចោទ និងចុងចម្លើយមិនលើកយកមកកំណត់អ្នកមានអំណាចមេបាលើកូនទី១នោះទេ។

### ៣-២.សេចក្តីសន្និដ្ឋាន

ការរួមរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយបង្កើតកូនចំនួន ០២នាក់ ដែលកូនទី០១ ដើមចោទ និង



Scanned with CamScanner

ចុងចម្លើយមិនលើកយកមកពិចារណាដោយហេតុថា កូនទី០១គ្រប់នីតិភាព ដូច្នេះតុលាការមិនលើកយកមកពិចារណានោះទេ។ ប៉ុន្តែ កូនទី២ឈ្មោះ[redacted]សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាកំណត់យកដើមចោទជាអ្នកមានអំណាចមេបា។ តុលាការទទួលស្គាល់ថាកំណត់យក ដើមចោទជាអ្នកមានអំណាចមេបាលើកូនទី២ មានផលប្រយោជន៍ដល់កូននេះ និងជាការព្រមព្រៀងរវាងដើមចោទ និងចុងចម្លើយក្នុងការកំណត់យកអ្នកមានអំណាចមេបាលើកូន ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការព្រម ព្រៀងរបស់ដើមចោទ និងចុងចម្លើយ យោងមាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែ ចុងចម្លើយដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ដើមចោទដែលមានអំណាចមេបាលើកូន គប្បីសម្របសម្រួល និងបង្កលក្ខណៈងាយស្រួល ដល់ចុងចម្លើយក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនយោងមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

**៤.ការវិនិច្ឆ័យចំពោះការទាមទារបែងចែកទ្រព្យសម្បត្តិ៖**

**៤.១-ការទទួលស្គាល់អង្គហេតុ៖**

៤.១.១-ដើមចោទអះអាងថាម៉ូតូរ៉ឺម៉កចំនួន ១(មួយ)គ្រឿង ទិញក្នុងតម្លៃចំនួន ១.៥០០ដុល្លារអាមេរិក។

៤.១.២-ដើមចោទទទួលស្គាល់ថា ការរួមរស់ជាមួយគ្នាចុងចម្លើយ និងដើមចោទបានចាក់ដី និងសង់ផ្ទះនៅលើដីដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ។

**៤.២-សន្និដ្ឋាន**

ផ្អែកតាមការសរុបនូវអង្គហេតុតុលាការទទួលស្គាល់ថា ទ្រព្យរួមមានម៉ូតូរ៉ឺម៉កចំនួន១(មួយ)គ្រឿង ទិញក្នុងតម្លៃ ១.៥០០(មួយពាន់ប្រាំរយ)ដុល្លារអាមេរិក និងបានចាក់ដី និងសាងសង់ផ្ទះ។ ដើមចោទយល់ព្រមប្រគល់ម៉ូតូរ៉ឺម៉កចំនួន ១(មួយ)គ្រឿងទិញក្នុងតម្លៃ ១.៨០០(មួយពាន់ប្រាំបីរយ)ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយដោយចុងចម្លើយព្រមទទួលយក ត្រង់ចំណុចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរវាងដើមចោទនិងចុងចម្លើយ ប៉ុន្តែចំពោះទំហំសោហ៊ុយចំណាយក្នុងការចាក់ដី និងសាងសង់ផ្ទះ ដើមចោទ និងចុងចម្លើយបានលើកឡើងនូវទំហំសោហ៊ុយចំណាយខុសគ្នា លើសពីនេះទៅទៀតដើមចោទនិងចុង ចម្លើយមិនមានឯកសារឬភស្តុតាងណាមួយដើម្បីបញ្ជាក់អំពីសោហ៊ុយចំណាយក្នុងការចាក់ដី និងសាងសង់ផ្ទះឡើយ ដោយដើមចោទបានអះអាងថា ការចំណាយសរុបគឺមានទឹកប្រាក់ចំនួន ៣.៥០០(បីពាន់ប្រាំបីរយ)ដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយបានបញ្ជាក់ថា ចុងចម្លើយបានយកប្រាក់ចំនួន ១២.០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ដើម្បីចាក់ដី និងសាងសង់ផ្ទះ ត្រង់ចំណុចនេះ ដើមចោទសុំប្រគល់ប្រាក់ចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក ទៅ ឱ្យចុងចម្លើយ ប៉ុន្តែ ចុងចម្លើយទាមទារប្រាក់ចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក តាមការពិនិត្យជាក់ស្តែង ឃើញថាការចំណាយជាក់ស្តែងសោហ៊ុយចំណាយ ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក។ ដូច្នេះ សោហ៊ុយចំណាយចាក់ដី និងសាងសង់ផ្ទះម្នាក់ៗ ចំណាយប្រាក់អស់ចំនួន ៣.៤០០(បីពាន់បួនរយ)ដុល្លារអាមេរិក ប៉ុន្តែដើមចោទ បានយល់ព្រមប្រគល់ម៉ូតូរ៉ឺម៉កចំនួន១(មួយ)គ្រឿង តម្លៃ១.៨០០(មួយពាន់ប្រាំបី)ដុល្លារអាមរិក ឱ្យទៅចុងចម្លើយ ដូច្នេះ ទ្រព្យសម្បត្តិរួមសរុបមាន ម៉ូតូរ៉ឺម៉កតម្លៃ ១.៨០០(មួយពាន់ប្រាំបីរយ)ដុល្លារអាមេរិក និងសោហ៊ុយចាក់ដី ព្រមទាំងសាងសង់ផ្ទះចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក ដូច្នេះទ្រព្យសម្បត្តិរួមសរុបមានតម្លៃ ៦.៨០០(ប្រាំមួយពាន់ប្រាំបីរយ)ដុល្លារអាមេរិក ដូច្នេះដើមចោទ និងចុងចម្លើយម្នាក់ៗទទួលបាន ចំណែកទ្រព្យរួមម្នាក់ពាក់កណ្តាល គឺមានទឹកប្រាក់ចំនួន ៣.៤០០(បីពាន់បួនរយ)ដុល្លារអាមេរិក ដោយដើមចោទយកផ្ទះដែលមានតម្លៃចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក ចុងចម្លើយយកម៉ូតូរ៉ឺម៉កតម្លៃ១.៨០០(មួយពាន់ប្រាំបីរយ)ដុល្លារអាមេរិក ដូច្នេះ ដើមចោទត្រូវបង់ប្រាក់ចំនួន ២.៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយ។

**៥.ការវិនិច្ឆ័យចំពោះការទាមទារប្រាក់ប្រដាប់ក្តី៖**

-ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ដោយសារដើមចោទបានបង់រួចទៅហើយ គប្បីតុលាការសម្រេចឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី យោងតាមមាត្រា៦២ និងមាត្រា៦៣នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១-បញ្ឈប់ការរស់នៅបែបអនីតិសង្វាស រវាងដើមចោទឈ្មោះ [redacted] ស៊ីឡុន និងចុងចម្លើយឈ្មោះ [redacted] ណាត តាមការព្រមព្រៀងគ្នា។

២-កំណត់ថាដើមចោទ ជាអ្នកមានអំណាចមេបាលើកូនម្នាក់ឈ្មោះ [redacted] សុវីរៈ ភេទប្រុស កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។ ភាគីចុងចម្លើយ ដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដើមចោទដែលជាអ្នកមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលគ្មានអំណាចមេបា តាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី តាមការព្រមព្រៀងគ្នា។

៣-ប្រគល់ម៉ូតូរ៉ឺម៉កចំនួន ១(មួយ)គ្រឿង និងប្រាក់ចំនួន ២.៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក ឱ្យទៅភាគីចុងចម្លើយឈ្មោះ សាន់ ណាត។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

-សាលក្រមនេះ ប្រកាសប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវធ្វើឡើងនៅក្នុងរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
តាកែវ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤
**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
តាកែវ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
តាកែវ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner